**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជានៅកំពង់សោម**
**ថ្ងៃទី២៦ មីនា ២០១៧**

អត្ថបទទី១៖ ១សម ១៦,១ខ.៦-៧.១០-១៣ក
អត្ថបទទី២៖ អភ ៥,៨-១៤
ដំណឹងល្អ៖ យហ ៩,១-៤១

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងបានស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូយ៉ាងពិសេស ណែនាំឲ្យយើងឃើញអំពីរបៀបរបស់ព្រះយេស៊ូ។ ពីសប្តាហ៍មុន ព្រះយេស៊ូជាទឹកដែលផ្តល់ជីវិតអស់កាលជានិច្ច ថ្ងៃនេះព្រះយេស៊ូណែនាំឲ្យមនុស្សខ្វាក់មើកឃើញ គេថាព្រះយេស៊ូជាពន្លឺ។ ថ្ងៃយើងមានបុរសម្នាក់ដែលខ្វាក់ពីកំណើត តាមជំនឿរបស់គេថាមនុស្សដែលខ្វាក់ពីកំណើតដោយសារគាត់ជាមនុស្សដែលពោរពេញដោយអំពើបាប។ បុរសនោះគាត់ជួយជាមួយព្រះយេស៊ូ គាត់មិនដឹងថាជាព្រះយេស៊ូទេ ក៏ប៉ុន្តែព្រះយេស៊ូបានចាប់អារម្មណ៍ជាមួយគាត់ "**ព្រះយេស៊ូយាងចេញពីព្រះវិហារទតឃើញមនុស្សខ្វាក់តាំងពីកំណើតមក**" ព្រះយេស៊ូចាប់អារម្មណ៍ជាមួយមនុស្សដែលកំពុងមានបញ្ហា ហើយព្រះអង្គណែនាំឲ្យមនុស្សខ្វាក់នេះមើលឃើញ "**សូមអញ្ជើញទៅលុបមុខនៅស្រះស៊ីលោមទៅ**"។ យើងត្រូវការចាប់អារម្មណ៍អំពីបងប្អូនទាំងអស់ដែលនៅជុំវិញគាត់ គ្មាននរណាម្នាក់ដែលចូលរួមនៅក្នុងអំណរសប្បាយជាមួយបុរសនោះសោះ រហូតដល់គេនាំគ្នាបណ្តេញគាត់តែម្តងដោយសារគេយល់ថាមនុស្សនេះពោរពេញដោយអំពើរបាប "**ឯជាមនុស្សជាប់បាបពេញខ្លួនទាំងពីកំណើតមក ហើយឯងហានប្រដៅយើងទៀត**"។ នៅពេលគាត់ចេញទៅខាងក្រៅគាត់បានជួបព្រះយេស៊ូម្តងទៀត ទោះគេបណ្តេញគាត់ប៉ុន្តែព្រះយេស៊ូនៅដើម្បីស្វាគមន៍គាត់។ ពេលជួបលើកទីមួយព្រះយេស៊ូណែនាំឲ្យគាត់មើលឃើញ ពេលជួបលើកទីពីរព្រះយេស៊ូបានបើកដួងចិត្តរបស់គាត់ ហើយគាត់ទទួលស្គាល់ថាព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់ "**លោកម្ចាស់ តើនរណាជាបុត្រមនុស្ស សូមប្រាប់ខ្ញុំឲ្យដឹងផង ដើម្បីឲ្យខ្ញុំជឿសង្ឃឹមលើព្រះអង្គនោះ**" ព្រះយេស៊ូមានព្រះបន្ទូលថា "**អ្នកឃើញលោកស្រាប់ គឺលោកដែលកំពុងតែនិយាយជាមួយអ្នកនឹងហើយជាបុត្រមនុស្ស**" នៅពេលនោះគាត់បើកភ្នែកមួយទៀត គឺភ្នែកនៃដួងចិត្តរបស់គាត់។ គាត់ទូលព្រះយេស៊ូថា "**បពិត្រព្រះអម្ចាស់ ទូលបង្គំជឿហើយ**" ហើយគាត់ក្រាបថ្វាយបង្គំព្រះអង្គ។ នេះជាអ្វីដែលព្រះយេស៊ូបានណែនាំឲ្យគាត់ភ្លឺទីមួយភ្លឺភ្នែក ទីពីរភ្លឺចិត្ត ព្រះយេស៊ូ

ណែនាំឲ្យគាត់បើកភ្នែកនៃដួងចិត្តរបស់គាត់ ដើម្បីឲ្យគាត់មានជំនឿលើព្រះជាម្ចាស់ និងណែនាំឲ្យគាត់មានសេចក្តីសង្ឃឹមជានិច្ច ទោះបីគេបណ្តេញគាត់ហើយ ព្រះយេស៊ូគង់នៅជាមួយគាត់និងណែនាំគាត់ឲ្យគាត់ទទួលពន្លឺថ្មីនៅក្នុងជីវិត។ នេះជាផ្លូវនៃជីវិតយ៉ាងពិសេស ព្រះយេស៊ូជាទឹក ព្រះយេស៊ូជាពន្លឺ និងព្រះអង្គណែនាំឲ្យយើងធ្វើដំណើរដូចអ្នកខ្វាក់នៅក្នុងជីវិតរបស់យើងដែរ។

ជីវិតរបស់យើងប្រៀបដូចជាផ្លូវមួយ ថ្ងៃណាមួយយើងជួបឧបសគ្គ បងប្អូនដែលនឹងទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងរាត្រីបុណ្យចម្លងខាងមុខនេះ បានធ្វើដំណើរជាមួយព្រះយេស៊ូដើម្បីបើកភ្នែកនៃរូបកាយ (អំណរសប្បាយជាមួយគ្រីស្តបរិស័ទ អំណរសប្បាយដែលជួបមិត្តសម្លាញ់ថ្មី...) លើកទីពីរអំណរសប្បាយរបស់គាត់ ណែនាំឲ្យគាត់ជួបជាមួយព្រះយេស៊ូ នេះជាពន្លឺថ្មីមួយនៃជីវិតរបស់គាត់ដើម្បីមានជីវិតថ្មី។ ដំណើរនៃជីវិតរបស់យើង ក៏ដូចគ្នាដែរ ក្នុងរដូវ៤០ថ្ងៃនជាឱកាសមួយដើម្បីបើកភ្នែកសារជាថ្មី ដោយមើលឃើញបងប្អូនឯទៀតៗ។ ឆ្នាំនេះសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានណែនាំឲ្យយើងគិតអំពីអត្ថបទគម្ពីរមួយយ៉ាងពិសេសនៅក្នុងរដូវ៤០ថ្ងៃ គឺអត្ថបទលោកឡាសាដែលជាអ្នកក្រីក្រ ពីមួយថ្ងៃទៅមួយថ្ងៃគាត់នៅមាត់ទ្វារផ្ទះរបស់អ្នកមានម្នាក់ ប៉ុន្តែអ្នកមាននេះមិនដែលមើលលោកឡាសាសោះ ដោយសារភ្នែករបស់គាត់មិនចង់មើលភាពក្រីក្រទេ ភ្នែករបស់គាត់ចង់តែមើលទ្រព្យសម្បត្តិ។ ពេលយើងទៅមាត់ទន្លេ យើងឃើញមានអាគារកាស៊ីណូណាហ្គរើលធំណាស់មានអាគារធំៗ ប៉ុន្តែនៅក្បែរនៅមានអ្នកក្រីក្រច្រើនណាស់ដែលគេមើលមិនឃើញ ដោយសារភ្នែករបស់គាត់វង្វេងជាមួយទ្រព្យសម្បត្តិ មានអំនួតពេញខ្លួនចង់បង្ហាញថាគាត់ជាអ្នកមាន។ ដូច្នេះ ភ្នែករបស់គាត់មិនអាចមើលឃើញទុក្ខលំបាករបស់អ្នកក្រីក្របានទេ។ ប៉ុន្តែនៅពេលយើងបានជួបជាមួយព្រះយេស៊ូ យើងត្រូវតែបើកភ្នែកនៃដួងចិត្តរបស់យើង ដើម្បីមើលឃើញទុក្ខលំបាកដូចព្រះយេស៊ូ។ ព្រះយេស៊ូឃើញមនុស្សខ្វាក់នៅពេលព្រះអង្គកំពុងធ្វើដំណើរ ទោះបីមានមនុស្សច្រើនក៏ដោយ។ នៅពេលគេបណ្តេញអ្នកខ្វាក់នោះ ព្រះយេស៊ូនៅដើម្បីស្វាគមន៍គាត់។ នេះជារបៀបនៅក្នុងរដូវ៤០ថ្ងៃនេះយើងត្រូវការទទួល ជំនឿរបស់យើងណែនាំឲ្យមានផ្លែនៃជំនឿគឺសេចក្តីស្រឡាញ់។ បងប្អូនអាចរស់ជំនឿផ្ទាល់ខ្លួនតាមរយៈសេចក្តីស្រឡាញ់ដែលបងប្អូនមានសម្រាប់អ្នកដទៃ។ យើងអាចបង្ហាញធម៌មេត្តាករុណាចេញពីដួងចិត្តរបស់យើងពិត លុះត្រាតែយើងមានជំនឿ។ ក្នុងរដូវ៤០ថ្ងៃនេះ យើងសូមព្រះ

ជាម្ចាស់ជួយយើងឲ្យយើងមានជំនឿថែមទៀត ដើម្បីឲ្យភ្នែកនៃដួងចិត្តរបស់យើអាចមើលឃើញទុក្ខលំបាករបស់បងប្អូនឯទៀតៗ ដោយសារ**បងប្អូនឯទៀតៗជាព្រអំណោយទានដែលយើងបានទទួលពីព្រះជាម្ចាស់**។ ដូច្នេះសូមបងប្អូនភ្ញាក់សារជាថ្មី ដូចយើងបានស្តាប់នៅក្នុងអត្ថបទទីពីរ "**អ្នកដេកលក់អើយចូរភ្ញាក់ឡើង ចូរក្រោកឡើងចេញពីចំណោមមនុស្សស្លាប់ ព្រះគ្រីស្តនឹងបំភ្លឺចាំងមកលើអ្នកហើយ**"។ នេះជាឱកាសមួយ ដើម្បីភ្ញាក់ស្មារតីដើម្បីក្រោកឡើង ដើម្បីចេញពីក្នុងចំណោមមនុស្ស និងដើម្បីចែករំលែកអំណរសប្បាយនិងជីវិតដែលយើងបានទទួលពីព្រះយេស៊ូជាមួយបងប្អូនឯទៀតៗ។ រៀងៗខ្លួន តើយើងធ្វើអ្វីខ្លះដើម្បីចែករំលែកសេចក្តីស្រឡាញ់ កុំឲ្យយើងទុកចោលអ្នកកំពុងស្លាប់លើផ្លូវ ប៉ុន្តែឲ្យយើងចេះបើកភ្នែកនៃរូបកាយរបស់យើង និងភ្នែកនៃដួងចិត្តរបស់យើង ដើម្បីឲ្យសេចក្តីស្រឡាញ់ហៀរចេញពីក្នុងខ្លួនរបស់យើង នៅក្នុងគ្រប់សកម្មភាពដែលយើងធ្វើពីមួយថ្ងៃទៅមួយថ្ងៃ។

ដើម្បីឲ្យយើងទៅមុខបាន សម្តេចប៉ាបបានរំលឹកយើងឲ្យយើងអានដំណឹងល្អ **គម្ពីរដំណឹងល្អជាអំណោយទានរបស់ព្រះជាម្ចាស់ផ្ទាល់** ប្រសិនបើយើងមិនស្គាល់ព្រះបន្ទូលរបស់ព្រះយេស៊ូ ប្រសិនបើយើងមិនស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ តើយើងធ្វើដូចម្តេចដើម្បីស្គាល់ព្រះអង្គយ៉ាងច្បាស់បាន។ ព្រះនាងម៉ារីបានស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយព្រះនាងម៉ារីបានទទួលស្វាគមន៍ព្រះបន្ទូលនៅក្នុងជីវិត ព្រះនាងម៉ារីបានឆ្លើយដល់ព្រះបន្ទូលនេះ **ខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់ សូមឲ្យបានសម្រេចតាមពាក្យរបស់លោកចុះ**។ ព្រះនាងម៉ារី បានស្តាប់ព្រះបន្ទូល ស្វាគមន៍ព្រះបន្ទូល ឆ្លើយតបព្រះបន្ទូលដើម្បីឲ្យព្រះយេស៊ូយាងមកនៅក្នុងពិភពលោកនេះ។ បើព្រះនាងម៉ារីមិនឆ្លយតបឥតមានព្រះយេស៊ូ បើឥតមានព្រះយេស៊ូឥតមានព្រះសហាគមន៍។

ថ្ងៃនេះយើងមានអំណរសប្បាយ ដោយដឹងថាយើងមានគំរូច្រើនដែលណែនាំឲ្យយើងភ្ញាក់ និងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងច្បាស់។ នៅពេលយើងចូលអភិបូជាស្តាប់ព្រះបន្ទូល សូមទុកព្រះបន្ទូលដែលយើងស្តាប់ប្រចាំថ្ងៃ ណែនាំឲ្យយើងមានសេចក្តីសង្ឃឹម។ សត្វគោមានក្រពះពីរ ពេលវាស៊ីស្មៅចូលក្នុងក្រពះទីមួយមួយរយៈពេលយូរទើបបញ្ជូនទៅក្រពះទីពីរដើម្បីផលិតទឹកដោះ។ ដូចគ្នាដែរ ឲ្យយើងទទួលគម្ពីរនៅក្នុងខ្លួនយើងយ៉ាងយូរ ឲ្យព្រះបន្ទូលបង្កើតជាជីវិតតាមសេចក្តីស្រឡាញ់ដែលយើងមាន។ ក្នុងរដូវ៤០ថ្ងៃ

នេះ ជាឱកាសមួយដើម្បីអានគម្ពីរថែមទៀត ដើម្បីស្រឡាញ់បងប្អូនថែមទៀត ដើម្បីធ្វើជាគ្រីស្តបរិស័ទដែលភ្លឺស្វាងដូចមនុស្សខ្វាក់អាចភ្លឺស្វាង រហូតដល់គាត់អាចប្រកាសថាពិតមែនព្រះយេស៊ូជាព្រះបុត្រា ពិតមែនព្រះយេស៊ូជាពន្លឺដែលបំភ្លឺជីវិតរបស់ខ្ញុំ ពិតមែនខ្ញុំមានអំណរសប្បាយ។ ទោះបីគេរិះគន់ខ្ញុំ ទោះបីគេមើលងាយខ្ញុំ ទោះបីគេមិនទទួលស្វាគមន៍ខ្ញុំ ខ្ញុំមានអំណរសប្បាយដោយសារខ្ញុំមានព្រះយេស៊ូដែលគង់នៅជាមួយខ្ញុំជានិច្ច។

ថ្ងៃយើងសូមអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គជួយបំភ្លឺយើង ឲ្យយើងចេះបើកភ្នែកមើលឃើញអ្នកដែលកំពុងខ្វាក់ ដែលគ្មានទីពឹងនៅក្នុងជីវិត ដើម្បីបើកបេះដូងរបស់យើង ដើម្បីឲ្យជំនឿរបស់យើងទៅជាសេចក្ដីស្រឡាញ់សម្រាប់បងប្អូនឯទៀតៗ។ សូមអរព្រះគុណព្រះជាម្ចាស់ ដែលប្រទានព្រះបុត្រាដើម្បីឲ្យយើងទទួលពន្លឺថ្មី ឲ្យយើងទទួលជីវិតថ្មី។ អាម៉ែន។